**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតតំបន់អភិវឌ្ឍន៍ទួលតាឯក

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បី ការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា" ឱ្យស្របជាមួយបទបញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.-**

បង្កើតតំបន់អភិវឌ្ឍន៍មួយ ដាក់ឈ្មោះថា " **តំបន់អភិវឌ្ឍន៍រុនតាឯក** " ។

**មាត្រា២.-**

ទីតាំងនៃតំបន់អភិវឌ្ឍន៍ ស្ថិតនៅក្នុងភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី និងក្នុងភូមិស្វាសង្គ្រាម ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ តំបន់អភិវឌ្ឍន៍នេះមានទំហំដីចំនួន **មួយពាន់ដប់ពីរ ក្បៀសប្រាំ** (១ ០១២, ៥ ) **ហិកតា** ស្ថិតនៅត្រង់ចន្លោះចំណុចដូចខាងក្រោម :

- ចំណុច **ក** ខ្សែរយៈបណ្តោយ **៣៨៤ ០០០** និងខ្សែរយៈទទឹង **១ ៤៥២ ០០០**
- ចំណុច **ខ** ខ្សែរយៈបណ្តោយ **៣៨៨ ៥០០** និងខ្សែរយៈទទឹង **១ ៤៥២ ០០០**
- ចំណុច **គ** ខ្សែរយៈបណ្តោយ **៣៨៨ ៥០០** និងខ្សែរយៈទទឹង **១ ៤៨៥ ៥២០**
- ចំណុច **ឃ** ខ្សែរយៈបណ្តោយ **៣៨៤ ០០០** និងខ្សែរយៈទទឹង **១ ៤៨៥ ៨០០**

**មាត្រា៣.-**

តំបន់អភិវឌ្ឍន៍នេះត្រូវបានប្រគល់ជូនអាជ្ញាធរអប្សរា ជាអ្នកគ្រប់គ្រង និងរៀបចំការអភិវឌ្ឍន៍តាមទិសដៅរបស់រាជរដ្ឋាភិបាល និងក្នុងការងារដោះស្រាយបញ្ហាសំណង់លំនៅដ្ឋានថ្មីរបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅ ក្នុងតំបន់១ និងតំបន់២ នៃរមណីយដ្ឋានអង្គរសព្វថ្ងៃ។

**មាត្រា៤.-**

អាជ្ញាធរអប្សរា ជាអ្នកទទួលបន្ទុករៀបចំប្លង់អភិវឌ្ឍន៍តំបន់នេះ ដើម្បីបង្កលក្ខណៈងាយស្រួល ជូនដល់ប្រជាពលរដ្ឋ ដែលត្រូវចេញពីតំបន់អង្គរទៅរស់នៅក្នុងតំបន់នោះ អាចរស់នៅបានយ៉ាងសមរម្យនិង មានការអភិវឌ្ឍន៍នាពេលអនាគត ។

**មាត្រា៥.-**

អាជ្ញាធរអប្សរាជាអ្នកទទួលបន្ទុកចុះអង្កេតរាល់ការកាន់កាប់ និងប្រើប្រាស់ដី នៅក្នុងតំបន់នេះ របស់ប្រជាពលរដ្ឋ ហើយសហការជាមួយអាជ្ញាធរដែនដី ដើម្បីដោះស្រាយគោលនយោបាយឱ្យបាន សមស្រប។

**មាត្រា៦.-**

អនុក្រឹត្យនេះ និរាករណ៍រាល់លិខិតពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លីក្នុងតំបន់នេះ ដូចមានភ្ជាប់ប្លង់ក្នុងឧបសម្ព័ន្ធ១ ។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០៤

ហ៊ុន សែន

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- កាលប្បវត្តិ-ឯកសារ




| កូដ | X | Y |
|---|---|---|
| ក | ៣៩៤០០០ | ១៤៩២០០០ |
| ខ | ៣៩៨៥០០ | ១៤៩២០០០ |
| គ | ៣៩៨៥០០ | ១៤៨៩៥២០ |
| ឃ | ៣៩៤០០០ | ១៤៨៩៨០០ |

# តំបន់អភិវឌ្ឍន៍_រុនតាឯក

